# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

**ខែសីហា-កញ្ញា ឆ្នាំ២០១៩ /August-September 2019**

## មាតិកា


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប/Executive summary** | **១** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends** | **៣** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់/Consumer price index | ៣ |
| ១.២. វិស័យហិរញ្ញវត្ថុ/Finance | ៤ |
| ១.៣. វិស័យពាណិជ្ជកម្ម/Trade | ៥ |
| ១.៤. ការអនុវត្តថវិកា/Budget execution | ៨ |
| ១.៥. វិស័យវិនិយោគឯកជន/Private investment | ៩ |
| ១.៦. វិស័យទេសចរណ៍/Tourism | ១១ |
| ១.៧. វិស័យសំណង់/Construction | ១២ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗ /Commodity prices** | **១៤** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ១៤ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១៥ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១៦ |
| **៣. ឧបសម្ព័ន្ធ** | **១៧** |

## ខ្លឹមសារសង្ខេប / Executive summary

**១.** តាមរយៈទិន្នន័យផ្លូវការពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (Admin Data) បានបង្ហាញថា ក្នុងរយៈពេល ៩ខែ ឆ្នាំ២០១៩ ការនាំចេញទំនិញរបស់កម្ពុជា សម្រេចបានទំហំទឹកប្រាក់សរុប ១០ ៨៧៤ លានដុល្លារ (៤០,៦% ធៀបនឹងផសស[1]) បានកើនឡើង ១៤,០% ធៀបរយៈពេលដូចគ្នាឆ្នាំមុន ដែលមានអត្រា ១៥,៥%។ កំណើននៃការនាំចេញសរុបមានការថមថយបន្តិច ដោយសារការថមថយកំណើននៃការនាំចេញផលិតផលសំខាន់ៗ ជាពិសេស កាត់ដេរនិងស្បែកជើង អង្ករ និងកង់។ ទន្ទឹមនេះ ការនាំចេញទៅកាន់ទីផ្សារសំខាន់ៗនៅតែបន្តកំណើនថមថយ បើធៀបនឹងអត្រាកំណើនក្នុងរយៈពេលដូចគ្នាឆ្នាំមុន លើកលែងតែការនាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក។ ចំណែកឯការនាំចូលមានទំហំទឹកប្រាក់សរុបចំនួន ១៥ ១៨៤ លានដុល្លារ (៥៦,៧% ធៀបនឹងផសស) បានកើនឡើង ១៩,៨% ទាបជាងកំណើនក្នុងរយៈពេលដូចគ្នាឆ្នាំមុន ដែលមានអត្រា ២៤,៣%។ កំណើនថមថយនេះ គឺបណ្ដាលមកពីការបន្តធ្លាក់ចុះនៃការនាំចូលផលិតផលវាយនភណ្ឌ (ពិសេសក្រណាត់) ខណៈពេលដែល ការនាំចូលផលិតផលសំខាន់ៗមួយចំនួនទៀតនៅតែបន្តរក្សាបានកំណើនរឹងមាំ។ ការនាំចូលក្រណាត់ដែលជាវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកាត់ដេរ បានថយចុះ ៥,២% ដែលការថយចុះនេះ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈការថមថយកំណើននៃការនាំចេញសម្លៀកបំពាក់។ ផ្ទុយទៅវិញ ការថមថយកំណើននៃការនាំចេញសម្លៀកបំពាក់នេះ ក៏ត្រូវបានប៉ះប៉ូវដោយកំណើនខ្ពស់នៃការនាំចេញផលិតផលវាយនភណ្ឌផ្សេងទៀត (ពិសេសផលិតផលធ្វើដំណើរ)។

**២.** ក្នុងរយៈពេល ៩ខែ ឆ្នាំ២០១៩នេះ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិសរុបប្រមាណ ៤,៨ លាននាក់ កើនឡើង ១០% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះភ្ញៀវទេសចរចិនមានចំនួន ១,៩ លាននាក់ ឬ៣៩% នៃភ្ញៀវទេសចរអន្តរជាតិសរុប (កើនឡើង ២៩%), វៀតណាម ១៣,២% (កើនឡើង ៩,១%) និងភ្ញៀវទេសចរអន្តរជាតិដទៃទៀត រួមមាន ឡាវ, ថៃ, កូរ៉េខាងត្បូង, អាមេរិក, ជប៉ុន, ម៉ាឡេស៊ី និងបារាំង។ ក្នុងកំណើនសរុប ១០% នេះ ភ្ញៀវទេសចរចិនបានចូលរួមចំណែកកំណើន (contribution to growth) ៩,៧%។ គួរបញ្ជាក់ផងដែរថា ភ្ញៀវទេសចរអន្តរជាតិចូលតាមច្រកសៀមរាបនៅតែបន្តធ្លាក់ចុះក្នុងអត្រា -១០,៩% ប៉ុន្តែប៉ះប៉ូវដោយកំណើននៃភ្ញៀវទេសចរអន្តរជាតិចូលតាមច្រកភ្នំពេញ និងកងកេង ដែលបន្តកើនក្នុងរង្វង់ ១២,៧% និង៣០៨%រៀងគ្នា។ ទោះបីជា ចំនួនភ្ញៀវទេសចរអន្តរជាតិសរុបមានការកើនឡើងក៏ដោយ ផលទុននៃសកម្មភាពទេសចរណ៍[2] បានធ្លាក់ចុះក្នុងអត្រា -១៧,៧% បើធៀបនឹងរយៈពេល៩ខែដូចគ្នាឆ្នាំមុន ពោលគឺថយចុះពី ៣២១,៤ ប៊ីលានរៀល នៅឆ្នាំ២០១៨ មកត្រឹម ២៦៤,៥ ប៊ីលានរៀន ក្នុងឆ្នាំ២០១៩ (ប្រភព÷ ចំណូលថិវការដ្ឋ, MEF)។

**៣.** គម្រោងវិនិយោគឯកជនក្រៅតំបន់សេដ្ឋកិច្ចពិសេសសរុប ក្នុងរយៈពេល ៩ខែ ឆ្នាំ២០១៩នេះ មានចំនួន **១៤៩** គម្រោង កើនឡើង ៥៥ គម្រោង (ភាគច្រើនវិនិយោគក្នុងវិស័យឧស្សាហកម្ម) និងមានទុនវិនិយោគប្រមាណ **៥ ៧៧៥** លានដុល្លារ កើនឡើង ៤៦,០៤% (កំណើនភាគច្រើនក្នុងវិស័យទេសចរណ៍បានមកពីទុនពីវិនិយោគិនកម្ពុជា) ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ***និន្នាការនេះបង្ហាញពីវឌ្ឍនភាពនៃកំណើនសហគ្រិនភាពក្នុងស្រុកលើវិស័យទេសចរណ៍ ស្របពេលដែលកំណើនការវិនិយោគក្នុងវិស័យឧស្សាហកម្មជាបច្ច័យក្នុងការបង្កើនល្បឿននៃឧស្សាហនីយកម្ម។*** ទោះជាយ៉ាងនេះក្តី កំណើនក្នុងវិស័យឧស្សាហកម្មភាគច្រើន បានមកពីគម្រោង

---

[1] ផសស (GDP at current price Million US$) = **២៦ ៧៨៦** លានដុល្លារ÷ យោងតាមតារាងMacro-framework ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩។

[2] ផលទុននៃសកម្មភាពទេសចរណ៍ សំដៅទៅលើចំណូលឆ្លងកាត់រតនាគារជាតិ ដែលរដ្ឋទទួលបានពីសកម្មភាពទេសចរណ៍ (អនុគណនី73003)។

វិនិយោគលើរោងចក្រកាបូប (កើន ៣៤ គម្រោង) ដែលបង្ហាញពីភាពមានកម្រិតនៃការធ្វើពិពិធកម្មវិស័យឧស្សាហកម្មនៅក្រៅតំបន់សេដ្ឋកិច្ចពិសេស។

៤. នៅខែសីហា ឆ្នាំ២០១៩នេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវាកម្មនៅរាជធានីភ្នំពេញ ***បានកើនឡើង ០,៩% ធៀបនឹងខែមុន និង ២,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន ។*** សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវាកម្មមួយចំនួនមានការកើនឡើងគួរឱ្យកត់សម្គាល់បើធៀបនឹងខែសីហាឆ្នាំមុន ក្នុងនោះ រួមមាន សន្ទស្សន៍ថ្លៃអាហារ និងភេសជ្ជៈមិនមានជាតិស្រវឹងកើនឡើង ២,៤%, ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់កើន ៦,១%, ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀតកើន ១,៧% និងភោជនីយដ្ឋានកើន ៦,៣%។ តាមរយៈទិន្នន័យបានបង្ហាញថា កំណើននេះបណ្តាលមកពីការកើនឡើងថ្លៃ អង្ករ សាច់មាន់ស្រស់ សាច់ទាស្រស់ ត្រីស្រស់ បន្លែ ថ្នាំជក់ ស្រា និងឧស្ម័ន។ ***តាមការធ្វើចំណោលដល់ខែធ្នូ ឆ្នាំ២០១៩ អត្រាអតិផរណាប្រចាំឆ្នាំ (Year on Year) និងអតិផរណាមធ្យមប្រចាំឆ្នាំ (Year Average) អាចមានអត្រាកំណើន ៣,២% និង ២,២%*** ដែលជាអត្រាស្ថិតក្នុងកម្រិតទាប និងមានស្ថិរភាពសម្រាប់ជាបច្ច័យល្អក្នុងការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ដើម្បីរក្សាបានចីរភាពកំណើន។

៥. គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ រដ្ឋបាលថ្នាក់ជាតិប្រមូលចំណូលក្នុងស្រុកសរុបបានចំនួន **១៧ ៧៧៣,៩** ប៊ីលានរៀល ឬស្មើនឹង **៨៩,៨%** នៃច្បាប់ឆ្នាំ២០១៩ កើនឡើង **២៦,១%** ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ដោយសារកំណើននៃប្រភេទចំណូលសំខាន់ៗមួយចំនួន ដូចជា ចំណូលមិនមែនសារពើពន្ធ **(៣២,១%)** ចំណូលពីពន្ធប្រយោល **(២៩,៤%)** និងចំណូលពីពន្ធពាណិជ្ជកម្មក្រៅប្រទេស **(២៦,៣%)** និងចំណូលពីពន្ធផ្ទាល់ **(១៤,៩%)**។ ទន្ទឹមនេះ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណាយសរុបបានចំនួន **១៤ ៥០៦,៨** ប៊ីលានរៀល ឬស្មើនឹង **៥៨,៩%** នៃច្បាប់ឆ្នាំ២០១៩ កើនឡើង **១,២%** ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ជាលទ្ធផល គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ តុល្យភាពថវិកាចរន្តមានអតិរេកសាច់ប្រាក់ចំនួន **៦ ៩១៧,២** ប៊ីលានរៀល និងតុល្យភាពថវិកាសរុបមានអតិរេកសាច់ប្រាក់ចំនួន **៣ ២៦៧,១** ប៊ីលានរៀល។

**៦.** ក្នុងរយៈពេល ៩ខែ ឆ្នាំ២០១៩នេះ សំណើសុំសាងសង់សរុបមានចំនួន ៣ ៣៣៨ គម្រោង កើនឡើង ៧៩៣ គម្រោង ក្នុងផ្ទៃក្រឡា ១២,៩ លាន ម៉ែត្រការ៉េ កើនឡើង ១៧,៨% និងមានតម្លៃ៦,៥ ប៊ីលានដុល្លារអាមេរិក កើនឡើង ៣៤,២% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ការសម្រេចបានកំណើនខ្ពស់នេះ គឺដោយសារកំណើននៃប្រភេទសំណង់ឧស្សាហកម្ម និងលំនៅដ្ឋានពិសេស សំណង់លំនៅដ្ឋាននៅរាជធានីភ្នំពេញ។

៧. គិតត្រឹមខែសីហា រូបិយវត្ថុទូទៅ M2 មានចំនួន ១០០,៦ ទ្រីលានរៀល បានកើនឡើង ២២,៥%ធៀបនឹងឆ្នាំមុន ក្នុងនោះប្រាក់រៀលនៅលើទីផ្សារមានចំនួន ១៦,២ ប៊ីលានរៀល បានកើនឡើងក្នុងអត្រា ២៦,៧% ធៀបនឹងឆ្នាំមុន។ ប្រាក់រៀលចរាចរលើទីផ្សារមានកំណើនជាមធ្យម ១៨%ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៨។

៨. នៅក្នុងខែកញ្ញា ឆ្នាំ២០១៩ ថ្លៃប្រេងសាំងធម្មតា និងប្រេងម៉ាស៊ូតលើទីផ្សារកម្ពុជា មានការថយចុះ ខណៈពេលដែល ថ្លៃប្រេងឆៅលើទីផ្សារអន្តរជាតិ មានការកើនឡើងវិញបន្តិចធៀបនឹងខែមុន។ ថ្លៃអង្ករលេខ១ និងអង្ករលេខ២ លើទីផ្សារកម្ពុជា ព្រមទាំងថ្លៃអង្ករលើទីផ្សារអន្តរជាតិ មានការថយចុះបន្តិចធៀបនឹងខែមុន។ ថ្លៃកៅស៊ូ (គ្រួសារជ័រកៅស៊ូស្ងួត) លើទីផ្សារកម្ពុជា ពុំមានការប្រែប្រួលទេ ខណៈពេលដែល នៅលើទីផ្សារអន្តរជាតិ ថ្លៃកៅស៊ូថៃ TSR20 ថយចុះ រីឯកៅស៊ូថៃ RSS3 កើនឡើង បើធៀបនឹងខែមុន។

## ១.១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index

### ក្រាហ្វិកបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ ក្រុម




ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ

## ១.២. វិស័យហិរញ្ញវត្ថុ / Finance

## ១.៣. វិស័យពាណិជ្ជកម្ម / Trades







ប្រភព÷ GDCE, MEF













ប្រភព÷ GDCE, MEF













ប្រភព÷ GDCE, MEF

## ១.៤. ស្ថានភាពការអនុវត្តថវិការដ្ឋ / Budget execution







ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ១.៥. ស្ថានភាពវិនិយោគ / Investment

ទោះបីជាមានកំណើននៃគម្រោងវិនិយោគយ៉ាងច្រើនក្នុងវិស័យឧស្សាហកម្ម ទុនវិនិយោគ
ក្នុងវិស័យនេះនៅមានភាពតិចតួចធៀបនឹងវិស័យផ្សេង




ទោះបីជាទុនវិនិយោគក្នុងវិស័យឧស្សាហកម្មតិចតួចជាងវិស័យផ្សេង កម្លាំងពលកម្មបង្កើត
ដោយវិស័យនេះបានចូលរួមចំណែកច្រើនជាងវិស័យផ្សេងទៀត




ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ១.៦. ស្ថានភាពទេសចរណ៍ / Tourism




ប្រភព៖ ក្រសួងទេសចរណ៍




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ១.៧. ស្ថានភាពសំណង់ / Construction




ប្រភព÷ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់

## ២. និន្នាការថ្លៃទំនិញសំខាន់ៗ / Commodity prices




ប្រភព÷ ក្រសួងពាណិជ្ជកម្ម




ប្រភព÷ ធនាគារពិភពលោក (Pink Sheet)




ប្រភព÷ ក្រសួងពាណិជ្ជកម្ម




ប្រភព÷ ធនាគារពិភពលោក (Pink Sheet)




ប្រភព÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




ប្រភព÷ Association of Natural Rubber Producing Countries (ANRPC)

**************

**<u>កំណត់សម្គាល់</u>**

កៅស៊ូ÷

- កៅស៊ូ TSR20: ឬហៅថាកៅស៊ូស្តង់ដារលេខ២០ រួមមានកៅស៊ូ SIR20, SMR20 និង STR20 គឺសំដៅលើកៅស៊ូធម្មជាតិដែលមានសារធាតុផ្សេងៗទៀត២០%។ កៅស៊ូធម្មជាតិមានច្រើនប្រភេទ ក្នុងនោះកៅស៊ូដែលមានតម្រូវការប្រើប្រាស់ច្រើនជាងគេគឺកៅស៊ូស្តង់ដារ (កៅស៊ូដុំ) និងកៅស៊ូបន្ទះ។ កៅស៊ូ TSR20 ជាប្រភេទកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ ផលិតកម្មកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើងនិងអាវភ្លៀងជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយលាយបញ្ចូល ជាមួយសារធាតុដទៃ ដែលធ្វើឱ្យផលិតផលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំ ធន់និងមិនងាយសឹករិចរិល។ ប្រទេសសំខាន់ៗដែលផលិតកៅស៊ូប្រភេទនេះគឺម៉ាឡេស៊ី ថៃ ឥណ្ឌូណេស៊ី វៀតណាម និងចិន។
- កៅស៊ូ RSS (Ribbed Smoked Sheets) បែងចែកជា៦ប្រភេទគឺ ប្រភេទលេខ 1, 2, 3, 4, 5 និងប្រភេទពិសេស មានពណ៌លឿងនិងវេចខ្ចប់ជាបន្ទះ។ កៅស៊ូប្រភេទ RSS3 ច្រើនផលិតនៅប្រទេសថៃ ឥណ្ឌា និងឥណ្ឌូណេស៊ី ប្រើប្រាស់ជាវត្ថុធាតុ សម្រាប់ផលិតសំបកកង់រថយន្ត បំពង់ទីបជ័រ និងស្បែកជើង។ កៅស៊ូប្រភេទនេះប្រើប្រាស់ក្នុងឧស្សាហកម្មផលិតសំបកកង់ រថយន្ត និងដែលជាធាតុផ្សំលើស 50% នៃផលិតផល។

ប្រេងឆៅ÷

ប្រេងឆៅ Brent, WTI និង Dubai ជាប្រភេទប្រេងឆៅធុនស្រាល (Light Crude Oil) ដែលមានការទិញលក់ច្រើនជាងគេ និងជាថ្លៃមូលដ្ឋានក្នុងការទិញលក់កិច្ចសន្យាអនាគត (Future Contract)។ ប្រេងឆៅលើទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នា ទៅតាមប្រភេទដូចជា÷ ប្រភេទប្រេង Brent ច្រើនផលិតនៅតំបន់សមុទ្រអាត្លង់ទិចខាងជើង, ប្រភេទប្រេងរបស់អាមេរិក WTI (West Texas Intermediate) និងប្រភេទប្រេងរបស់អារ៉ាប់ប៊ីសាអ៊ូឌីត Dubai។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈ ខុសគ្នាទៅតាមកម្រិតភាពស្រាល ហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់វាស់វែងភាពស្រាលនៃប្រភេទប្រេងឆៅនីមួយៗ។ ប្រភេទប្រេងដែលមានកម្រិត API Gravity កាន់តែខ្ពស់គឺជាប្រភេទប្រេងដែលកាន់តែស្រាល និងអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។

- WTI 40$^{o}$ API
- Brent 38$^{o}$ API
- Dubai 32$^{o}$ API

*រៀបចំដោយ*

*នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច*

*អគ្គនាយកដ្ឋានគោលនយោបាយ*

*ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧ ៩១៣, ០៩៨  ២២ ៨៤ ៩៤*

*ម៉ោងធ្វើការ÷ ៨:០០ ដល់ ១២:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*